ប៉ូគៀមបានក្លាយជារដ្ឋមន្ត្រីនៅក្នុងការដឹកនាំនៃ«រដ្ឋាភិបាលបដិវត្តន៍បណ្ដោះអាសន្ន» របស់យៀកកុង ។

នៅខែកក្កដា១៩៦៣, ក្នុងភូមិគ្រឹះមួយនោទីក្រុងកែប ប្របតាមឆ្នេរសមុទ្រនៃឈូងសមុទ្រសៀម, ត្រាន់-ប៉ូគៀម បានទទួលអ្នកសារពត៌មានជាបារាំង ហ្សិកហ្ស៍ហ្សាហ្វ៉ា ដែលគៀមបានផ្ដល់ការសម្ភាសន៍មួយ ដែលសារពត៌មាន ឡឺម៉ុង បានយកមកចុះផ្សាយនៅថ្ងៃទី២៨សីហា១៩៦៣, ហើយនៅឱកាសនោះ គៀមសំដែងដោយស្មុគ្រចិត្ត នូវសេចក្ដីសង្ឃឹមសំរាប់អនាគតនៃយួនខាងត្បូង ។

គេបានឃើញត្រាន់-ប៉ូគៀមផងដែរ នៅក្រុងភ្នំពេញក្នុងឆ្នាំ១៩៦៥ ប៉ុន្តែម្ដងនេះតាមផ្លូវការ ក្នុងនាមជាបុគ្គលិកទី២នៃគណប្រតិភូរបស់រណសិរ្សរំដោះយៀកកុង នាឱកាសសន្និសិទនៃប្រជាជនឥណ្ឌូចិន ដែលរៀបចំឡើងដោយស្ដេចសីហនុ។ ត្រាន់-ប៉ូគៀមបានអមដំណើរ មេដឹកនាំនៃគណប្រតិភូ វិញ-តាន់ផាត, ជាអនុប្រធាននិងជាអគ្គលេខាធិការនៃរណសិរ្សរំដោះយៀកកុង ដែលនៅពេលនោះជាប្រធាននៃរដ្ឋាភិបាលបដិវត្តន៍បណ្ដោះអាសន្នយៀកកុង ។ ដោយសារត្រាន់-ប៉ូគៀមបានទទួលអ្នកសារពត៌មាន២-៣នាក់នៅក្នុងបន្ទប់ដែលគៀមស្នាក់នៅឯសណ្ឋាគារមនោរម្យ ក្នុងក្រុងភ្នំពេញ, គៀមបានកត់សំគាល់ថា វិញ-តាន់ផាត ត្រូវបានការពារហ្មត់ចត់ ដោយ«ជើងខ្លាំងពីរបីនាក់នៃក្រសួងសន្តិសុខខ្មែរ» ។ ក្រុមអង្គរក្សទាំងនេះ ត្រូវបានចាត់តាំងសំរាប់សេចក្ដីត្រូវការរបស់ពួកមេដឹកនាំនៃរណសិរ្សរំដោះជាតិយៀកកុង និងគណប្រតិភូកុម្មុយនិស្តដទៃទៀត តាមបញ្ជាផ្ទាល់ពីសីហនុ ។

ប្រមុខរដ្ឋខ្មែរពេលនោះ បានទទួលមេដឹកនាំផ្សេងទៀត របស់រណសិរ្សរំដោះជាតិយៀកកុងជាច្រើនលើក, «សាស្ត្រាចារ្យ» ង្វៀង-វ៉ាន់ហៀវ, ជាអង្គទូតគោចរដែលជា«អ្នកផ្ដល់ពត៌មានសម្ងាត់»របស់ប្រាហ្គ, បេសកកម្មមួយក្នុងចំណោមបេសកកម្មទូតដំបូងទាំងឡាយរបស់អង្គការនេះ ។ ក្នុងពេល ង្វៀង-វ៉ាន់ហៀវ មកតាំងតំណាងអចិន្ត្រៃយ៍នៅភ្នំពេញ ក្នុងថ្ងៃទី១៩ កក្កដា ១៩៦៦, សីហនុបានពន្យល់ជាបន្ទាន់ ទោះជាផ្ទុយនឹងពិធីការ នូវលក្ខន្តិកៈសំរាប់ទូត ។ អំណើះតទៅ, រណសិរ្សរំ-ដោះជាតិយៀកកុង មានអភ័យឯកសិទ្ធិសំរាប់ស្ថានទូត ។ ភាពមិនអាចប៉ះពាល់បានក្នុងការឆ្លើយឆ្លងគ្នា ជាវត្ថុកម្រក្នុងរបបសីហនុ ដែលខុទ្ទកាល័យងងឹតមួយមានដំណើរការជានិច្ច- ទំនាក់ទំនងវិទ្យុ-ទូរលេខជាមួយរដ្ឋាភិបាលយៀកកុង ដោយរដ្ឋាភិបាលបដិវត្តន៍បណ្ដោះអាសន្នយៀកកុង នៅពុំទាន់មានរដ្ឋធានី, គេយល់អំពីការប្រើប្រាស់ដែលរណសិរ្សរំដោះជាតិយៀកកុងចាត់ចែង តាមរយៈស្ថានិយផ្សា-យនៅភ្នំពេញ ។ល។ សីហនុមិនបានរុញរាទេ ក្នុងការចាត់ទុក ង្វៀង-វ៉ាន់ហៀវ ជា«អង្គទូតខ្ពង់ខ្ពស់ ដែលត្រេកត្រអាលដោយទំនុកទុកចិត្ត និងការលើកតម្លៃពីយើង» ។

សីហនុ, ដោយអនុវត្តជាថ្មីម្ដងទៀតនូវ « ការសង្កត់បញ្ជាក់ដំណើរការ ដោយ

ត្រួតពិនិត្យការវិវត្តន៍», បានបោះជំហានជាលើកដំបូងទៅរកយៀកកុង, ដែលបានប្រកាសជាផ្លូវការ អំពីការសំរេចចិត្តរបស់គេ «ដើម្បីទទួលស្គាល់ និងគោរពព្រំដែនបច្ចុប្បន្នរបស់ខ្មែរ» តែនៅត្រឹមពេលជិតមួយឆ្នាំបន្ទាប់មក, ក្នុងថ្ងៃទី៦ មិថុនា ១៩៦៧ តាមរយៈលិខិតរបស់ ង្វៀង-ហ៊ឺ ថ, ជាប្រធានសភាររបស់គណៈកម្មាធិការមជ្ឈឹមក្នុងរណសិរ្សរំដោះជាតិយៀកកុង ។ ពីរឆ្នាំក្រោយមក, សីហនុទទួលស្គាល់រដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្នយៀកកុងតាមផ្លូវការ ដែលជាការប្រឆាំងទាំងស្រុងជាមួយរដ្ឋាភិបាលស្របច្បាប់នៅយួនខាងត្បូង, ហើយនៅថ្ងៃទី១៦ មិថុនា ១៩៦៩, ង្វៀង-វ៉ាន់ហៀវ ប្រគល់សារតាំងទៅសីហនុ ក្នុងឋានៈខ្លួនជាឯកអគ្គរដ្ឋទូតយៀកកុង ។ ដោយបន្តតាមអ្វីដែលគាត់ហៅថា នយោបាយ«អព្យាក្រិត»របស់គាត់, សីហនុបានទទួលសារតាំងពី ង្វៀង-ថុង, ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋប្រជាធិបតេយ្យយួនខាងជើងនៅកម្ពុជា ។

សីហនុពុំមែនមិនដឹងទេថា តាំងពីច្រើនឆ្នាំមកហើយ កងកម្លាំងយួនខាងជើង និងយៀកកុងបានមកតាំងនៅតាមផ្នែកទាំងឡាយ ដែលមិនសូវសំបូរប្រជាជនក្នុងរាជាណាចក្រ, នៅខេត្តនានាខាងភូមិភាគឦសាន ។ នៅខណៈដែលគាត់បានទទួលស្គាល់រដ្ឋាភិបាលឧទ្ទាម គឺរដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្នយៀកកុង, សីហនុជំទាស់, ព្រមពេលគ្នានិងជាលើកទីមួយ, ដល់ការកាន់កាប់នៅលើផ្នែកមួយចំនួននៃខេត្តទាំងឡាយរបស់ខ្មែរ ដោយពួកកុម្មុយនិស្តយួន ។ ក្នុងសន្និសិទសារពត៌មានរបស់គាត់ នៅថ្ងៃទី១១ មិថុនា ១៩៦៩ សីហនុបានអះអាងថា ក្នុងខេត្តរតនគីរីដែល



ស្តេចសីហនុកំពុងបង្ហាញផែនទីជំរកយៀកកុងនៅលើទឹកដីខ្មែរដល់ពួកអ្នកកាសែត (ថ្ងៃទី២៨ មិនា ១៩៦៩)

ជាប់នឹងយួនខាងត្បូង, ពួកយៀកកុងនិងយួនខាងជើង «បានមកតាំងនៅជាស្រេចតាមភូមិទាំងឡាយក្នុងតំបន់នានា ដែលស្ថិតនៅឆ្ងាយពីផ្លូវគមនាគមន៍, ប៉ុន្តែសំបូរដោយជីវជាតិ ហើយស្រោចស្រពដោយទន្លេ, ស្ទឹង, ព្រែកជាច្រើន ។ ពួកកុម្មុយនិស្តយួនបានតែងតាំង «អភិបាល»មួយសំរាប់ពួកគេ «ដែលមានមនុស្សប្រហែល ៦០នាក់ ប្រដាប់ដោយកាំភ្លើងស្វ័យប្រវត្តិចិន និងគ្រាប់បែក នៅក្រោមបញ្ជារបស់ពួកគេ», ដែលឆ្លងកាត់ «មួយខែម្តង តាមភូមិដើម្បីឃោសនានៅទីនោះ» ។ ក្នុងឱកាសសន្និសិទសារពត៌មាននេះ សីហនុចាប់ផ្តើមបើកកកាយអំពីរបបភេរវកម្មដែលសាបព្រួស ដោយពួកកុម្មុយនិស្តយួននិងពួកភ្នាក់ងាររបស់គេ ដែលរស់នៅតាមភ្នំក្នុងតំបន់ទាំងនេះ «អ្នកភូមិទាំងឡាយដែលស្មោះត្រង់ជាមួយរាជរដ្ឋាភិបាលខ្មែរត្រូវបានសម្លាប់ចោលតាមប្រព័ន្ធច្បាស់លាស់ ។ ដើម្បីសម្លាប់ជនទាំងនេះ មុនដំបូងគេចងដៃជើង រួចមកកចងរឹតកដោយខ្សែ ឬគាបកដោយដំបងឫស្សី» ។

កងទ័ពនៃរាជរដ្ឋាភិបាល, ដោយគ្មានគ្រឿងអាវុធគ្រប់គ្រាន់, មិនអាចកំចាត់បានទេ នូវអំពើឈ្លានពាននេះ, ដែលស្ថិតនៅក្រោមកិច្ចការពារសំងាត់ពីប្រមុខរដ្ឋខ្មែរ ។ មិនតែប៉ុណ្ណោះ, ចាប់ពីឆ្នាំ១៩៦៦, តាមបញ្ជាពីសីហនុ, រាជរដ្ឋាភិបាលបានអនុញ្ញាតលក់ទៅឲ្យយៀកកុង នូវអង្ករ៨០,០០០តោន គិតជាប្រាក់ដុល្លារ ។ លើសពីអង្ករមានការរត់ពន្ធគោ ក្របី ជ្រូក ក្រណាត់ កង់រថយន្ត សញ្ញាអង្គរ ជាមួយយៀកកុង ។ ការលក់ដូរទាំងនេះត្រូវបានគិតជាប្រាក់រៀលខ្មែរ ឬជាដុល្លារហុងកុង ។ សន្សឹមៗ ដែលការរត់ពន្ធទាំងនេះកាន់តែរីកដាលបន្តិចម្តងៗ, មួយផ្នែកនៃទឹកប្រាក់ដ៏ធំធេងបានធ្លាក់ក្នុងកណ្តាប់ដៃរបស់ឈ្មួញចិននិងយៀកកុង ដែលក្លាយទៅជាមធ្យោបាយមួយសំរាប់ពួកនេះ ក្នុងការធ្វើសម្ពាធលើរាជរដ្ឋាភិបាល ។

សីហនុគ្មានអនុភាពដើម្បីរើបំរះ, ព្រោះគាត់ពុំមែនមិនដឹងទេថា ក្រសួងតម្រួតទាំងមូលស្ថិតនៅក្រោមការកាន់កាប់របស់អ៊ុំ-ម៉ាណូរិន ដែលត្រូវជាបងប្រុសរបស់ជាយានៃប្រមុខរដ្ឋខ្មែរ ។ ម្យ៉ាងទៀតផ្សារលក់ទំនិញទាំងនេះ មានដំណើរការតាមសំដីផ្ទាល់មាត់ ដូចគ្នានឹង ការអនុវត្តន៍បែបនេះនៅតំបន់អាស៊ីជាមួយ«អាហារ័ណនីហរ័ណ», ជាក្រុមហ៊ុនសេដ្ឋកិច្ចចំរុះ មានបន្ទុកលើរាល់ប្រតិបត្តិការ«នាំចេញ-នាំចូល» ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៦៣ ក្នុងឱកាសធ្វើជាតូបនិយកម្មសេដ្ឋកិច្ច បន្ទាប់ពីការទាត់ចោលនូវជំនួយអាមេរិកាំង ។ នៅឆ្នាំ១៩៦៦, ក្រុមហ៊ុនត្រូវចូលក្នុងរដ្ឋូបនិយកម្ម ។

គឺចាប់ពីកាលបរិច្ឆេទនេះ ដែលការរត់ពន្ធទៅឲ្យយៀកកុង បានឡើងដល់កំរិតទូលំទូលាយបំផុត ដោយមិនរួមបញ្ចូលត្រឹមតែការផ្តល់នូវផលិតផលជាស្បៀងអាហារ និងសំលៀកបំពាក់ប៉ុណ្ណោះទេ ប៉ុន្តែកាន់តែធ្ងន់ខ្លាំង គឺការបញ្ជូនជាគ្រឿងអាវុធ និងសម្ភារៈចំបាំង ។ ចាប់ពីខែធ្នូ១៩៦៦ទៅដល់ខែមេសា១៩៦៩, គ្រឿងអាវុធនិងយុទ្ធោបករណ៍ទម្ងន់២១តោន ដែលត្រូវសំដៅទៅពួកកុម្មុយនិស្តយួន បានមក

ដល់កំពង់ផែនៅកំពង់សោម ហើយត្រូវបានបញ្ជូនទៅតំបន់ទល់ដែនខ្មែរ-យួន ជាទីដែលកងកម្លាំងយៀកកុងនិងយួនខាងជើងតាំងនៅ ។ តាមធម្មតាការដឹកជញ្ជូនគ្រឿងអាវុធពីកំពុងផៃហៃហ្វុង ដោយកាត់តាមប្រទេសខ្មែរនិងលាវ មកកាន់ទីតាំងទាំងឡាយរបស់យៀកកុងនៅយួនខាងត្បូង ត្រូវមានចម្ងាយ២,៨០០គ.ម. ។ ក្នុងដំណើរដ៏លំបាកតាមផ្លូវលំហូ-ជីមិញ ដែលប្រព្រិត្តទៅបានតែនៅក្រៅរដូវភ្លៀង រថយន្តបន្ទុក១៣,៨០០គ្រឿង ដែលដឹកគ្រឿងអាវុធនិងសម្ភារ:សឹក បានមកពីសូវៀត ចិន និងប្រទេសកុម្មុយនិស្តផ្សេងទៀត សំរាប់ផ្តល់ទៅឲ្យយៀកកុងនៅយួនខាងត្បូង ត្រូវបានកំទេចដោយកងអាកាសចរណ៍អាមេរិកាំង ។ ប៉ុន្តែ, ចម្ងាយផ្លូវពីកំពង់ផែកំពង់សោមទៅព្រំដែនខ្មែរ-យួន មានតែជាង៥០០គ.ម.ប៉ុណ្ណោះ ហើយប្រកបដោយសន្តិសុខគ្រប់គ្រាន់ ។ ការលក់គ្រឿងអាវុធ ក៏បានបានទទួលការចូលរួមដូចគ្នាជាមួយការរត់ពន្ធអង្ករ និងផលិតផលផ្សេងៗ ពីសំណាក់សមាជិករបស់ក្រុមគ្រួសារផ្ទាល់នៃជាយារបស់ប្រមុខរដ្ឋខ្មែរ ។

ខ្លួនខ្ញុំផ្ទាល់នៅចងចាំពាក្យពេចន៍ក្នុងសង្កថារបស់សីហនុនៅឆ្នាំ១៩៦៨ថា ៖ «បើចក្រពត្តិនិយមអាមេរិកាំងហ៊ានធ្វើសង្គ្រាម, ខ្មែរហ៊ានចំណេញ» ។ ប៉ុន្តែ, អនិច្ចា នៅដំណាច់ឆ្នាំ១៩៦៨ ក្នុងហិបប្រាក់ជាតិមានសល់តែ១៨០លានរៀលប៉ុណ្ណោះ ក្នុងចំណោមទឹកប្រាក់ដែលត្រូវមានដល់៧,០០០លានរៀល សំរាប់ចំណាយក្នុងប្រទេស គឺត្រឹមតែ២% ។ ធ្ងន់ធ្ងរជាងនេះទៅទៀត រាជរដ្ឋាភិបាលបានប្រកាសប្តូរក្រដាស់ប្រាក់៥០០រៀលថ្មី ពីព្រោះក្រដាស់ប្រាក់៥០០រៀលចាស់ ឬក្រដាស់ផាងត្រាវ ត្រូវបានយៀកកុងបោះពុម្ពដោយក្លែងបន្លំ ដើម្បីយកមកទិញផលិតផល ធនធានរបស់ខ្មែរ សំរាប់ធ្វើសង្គ្រាមនៅយួនខាងត្បូង ។ ជាលើកទី២ហើយ ដែលយួនប្រើស្មៀតនេះ ។ ក្នុងភាពយន្តឯកសារ «ឥណ្ឌូចិនបារាំង» វូ-កុកធឹក, ដែលនៅឆ្នាំ១៩៤៦ ជាសមាជិកនៃគណ:កម្មាធិការតស៊ូយៀកមិញ ហើយនៅឆ្នាំ១៩៥៥ ជារដ្ឋមន្ត្រីនៃរដ្ឋាភិបាលប៉ៅដាយ, និយាយអួតអាងទាំងញញឹមថា ៖ «ខ្ញុំដឹងថា ហូ-ជីមិញ បានប្រុងប្រៀបសង្គ្រាមតស៊ូជាមួយបារាំង ។ ខ្ញុំមានមិត្តភក្តិនៅក្នុងផ្នែករដ្ឋបាលហិរញ្ញវត្ថុនៃក្រសួងហិរញ្ញវត្ថុរបស់ហូ-ជីមិញ ។ គេបានចាប់ផ្តើមបោះពុម្ពក្រដាស់ប្រាក់ដែលមានរូបហូ-ជីមិញ, រួចហើយគេជំរុញឲ្យប្រជាជនយួនទាំងអស់ទូទាំងប្រទេសចាយវាយបញ្ជូលគ្នា ជាមួយក្រដាស់ប្រាក់ «ព្យាស» របស់«ធនាគារឥណ្ឌូចិនបារាំង» ដែលសំរាប់ចាយវាយក្នុងប្រទេសខ្មែរ លាវ និងយួន ។ លោកដឹងទេថា ក្រដាស់ប្រាក់ហូ-ជីមិញគ្មានតំលៃនៅលើផ្សារប្តូរប្រាក់អន្តរជាតិមែន ប៉ុន្តែក្រដាស់ប្រាក់ «ព្យាស»នៃឥណ្ឌូចិនបារាំង ត្រូវបានធានាអះអាងដោយអាជ្ញាធរនៃអាណាណិគមបារាំង ។ ដូច្នេះ គេមានថវិកាសំរាប់ធ្វើសង្គ្រាម ទិញគ្រឿងអាវុធ និងចេញប្រាក់បៀវត្សឲ្យអ្នករដ្ឋការនៅហាណូយ» ។ អ្វីៗទាំងនេះបានកន្លងផុតទៅហើយ ហើយត្រូវបញ្ចប់ត្រឹមពាក្យសារភាពរបស់សីហនុ ដែលត្រូវបានយកមកផ្សព្វផ្សាយ តាមវិទ្យុ

សម្លេងអាស៊ីនៅក្រុងប៉ារីសក្នុងឆ្នាំ១៩៨៩ថា ៖ «ខ្ញុំករុណាបានជួយយួនយ៉ាងសំបើម ក្នុងនាមអ្នកស្នេហាជាតិនៅជិតខាងគ្នា» ។

ក្នុងខែកក្កដា១៩៦៩, នៅភ្នំពេញ, បន្ទាប់ពីបានទទួល វិញ-តាន់ផាត ជាផ្លូវការតាមឋានៈជាប្រធាននៃរដ្ឋាភិបាលបដិវត្តន៍បណ្ដោះអាសន្នយៀកកុង, សីហនុ ពីរខែក្រោយមកបានចុះហត្ថលេខាជាមួយរដ្ឋាភិបាលនៃក្រុងហាណូយ និងរដ្ឋាភិបាលយៀកកុង សំរាប់រណសិរ្សនៅយួនខាងត្បូង លើ«កិច្ចព្រមព្រៀងពាណិជ្ជកម្មនិងការបង់ប្រាក់» ។ កិច្ចព្រមព្រៀងនេះ ដែលជាការធានាអះអាង ត្រូវបានសំរេចឡើងត្រឹមតែ ដើម្បីលាក់បាំងការបញ្ជូនគ្រឿងអាវុធទៅឲ្យយៀកកុងនិងយួនខាងជើងប៉ុណ្ណោះ ដែលពលទាហានពី៤០,០០០ទៅ៥០,០០០នាក់ បានមកតាំងទីជាស្រេចក្នុងដែនដីខ្មែរ ។ ត្រង់ចំណុចនេះហើយ ដែលពាក្យស្នើររបស់ សាឡុត-សរ នៅក្រុងហាណូយក្នុងឆ្នាំ១៩៦៥-១៩៦៦ ដើម្បីទទួលការអនុញ្ញាតសំរាប់ការតស៊ូផ្នែកអាវុធប្រឆាំងសីហនុនៅកម្ពុជា ត្រូវបានបដិសេធពីមេដឹកនាំយួន ហើយមេដឹកនាំគណប្រតិភូយួន ឡេ-យង់ បានពន្យល់ទាំង សាឡុត-សរ ទាំងខ្មែរយៀកមិញនៅហាណូយថា ៖ «ឲ្យផ្អាកការតស៊ូបដិវត្តន៍សិន ហើយរង់ចាំដល់យៀកណាមទទួលបានជ័យជំនះនៅយួនខាងត្បូង, ពេលនោះជោគជ័យនៃបដិវត្តន៍នៅកម្ពុជានឹងកើតមានដោយស្វ័យប្រវត្តិ» (បញ្ជីខ្មៅរបស់ប៉ុល-ពត, ទំព័រទី៣៨) ។ ប៉ុន្តែក្រោយមក, គំរោងរបស់យួនត្រូវប្រែប្រួល ដោយសាររដ្ឋប្រហារនៅឆ្នាំ១៩៧០ ហើយមកទល់ពេលនេះ មតិខ្មែរខ្លះយល់ស្របតាមសេចក្ដីអះអាងរបស់សីហនុថា ៖ «វិនាសកម្មនៅកម្ពុជា កើតមានត្រឹមតែដោយសាររដ្ឋប្រហារនៅឆ្នាំ១៩៧០» ។

នៅពីក្រោយឡប់ឡែនៃអព្យាក្រិតភាពរបស់គាត់, សីហនុបានបញ្ឆោត «កូនចៅជាទីស្នេហា»របស់គាត់ ដែលជនរួមជាតិស្លូតត្រង់ទាំងនេះប្រាថ្នាដោយស្មោះដើម្បីស្ថិតនៅជាអព្យាក្រិតពិតប្រាកដ ។ ចំណុចនេះជាបុព្វហេតុមួយ ក្នុងចំណោមបុព្វហេតុធ្ងន់ធ្ងរទាំងឡាយ ដែលបានបង្កជាការបែកបាក់ រវាងស្ដេចសីហនុនិងប្រជារាស្ត្រខ្មែរ ។ វិលវល់ក្នុងនយោបាយ និងជោគជាំដោយអភិមានះរបស់គាត់, សីហនុពុំបានដឹងខ្លួនទេ ហើយជាបរាជ័យរបស់គាត់ ។ បរាជ័យដែលខ្លួនគាត់ផ្ទាល់ជាអ្នករៀបចំដោយមិនដឹងខ្លួនតាំងពីយូរឆ្នាំមក ។ សីហនុមិនបានដឹងសោះថា ហាណូយចង់បំបាត់រាជាធិបតេយ្យខ្មែរ តាំងពីថ្ងៃទី៩សីហា១៩៤៥ ដោយបញ្ជូនឲ្យខ្មែរយៀកមិញ៧នាក់ទៅធ្វើពលប្រហារនៅក្នុងរាជវាំង ។ សីហនុបានចាត់ទុកថា ចិនជាមិត្តទីមួយ ដែលអាចបង្ក្រាបយួន, ពេលណាយួនឈ្លានពានខ្មែរ, ហើយចាត់ទុកយួនជាមិត្តទីពីរ ដែលអាចបង្ក្រាបខ្មែរកុម្មុយនិស្ត, ពេលណាខ្មែរកុម្មុយនិស្តចង់រំលំរាជាធិបតេយ្យ, ដោយសង្ឃឹមជានិច្ចថា យួនហាណូយជាចៅហ្វាយរបស់ខ្មែរកុម្មុយនិស្ត ហើយយួនត្រូវការរូបគាត់ជាងខ្មែរទាំងនោះ ។ (ផ្អែកតាមដានពត៌មាន តាមវិទ្យុសម្លេងនៅបរទេស អាស៊ី-ប៉ាស៊ីហ្វិក, ថ្ងៃទី១១មេសា១៩៦៨) ។ ដោយជឿជាក់យ៉ា

ងអស់ពីចិត្តថា កុម្មុយនិស្តនៅអាស៊ីនឹងបានជ័យជំនះនៅទីបំផុត, សីហនុបានចំ-ពេញរាល់អ្វីៗដើម្បីទទួលបានការសណ្តោសប្រណី ពីមេកុម្មុយនិស្តទាំងនេះទៅអនាគត ។

ប៉ុន្តែ, មួយឆ្នាំមុនសន្និសិទកំពូលរបស់ប្រជាជននៅឥណ្ឌូចិន, សីហនុគេចមិនផុតពីការសារភាព អំពីវត្តមានរបស់យៀកកុងនិងយួនខាងជើងក្នុងកម្ពុជា ។ នៅថ្ងៃទី៦មិនា១៩៦៩, ក្នុងឱកាសសន្និសិទសារព័ត៌មានមួយ, សីហនុបានបើកកកាយ«គ្រោះធំក្នុងអនាគតខ្លី និងតាមកំណាត់» ដែលបណ្តាលមកពី«ការជ្រៀតចូលនៃពួកកុម្មុយនិស្តយួន» ។ នាសម័យសន្និសិទសារព័ត៌មាននេះ, សីហនុចង្អុលបង្ហាញតាមផែនទីរបស់សេនាធិការដ្ឋាន អំពីតំបន់ទាំងឡាយក្នុងប្រទេស «ដែលពួកយួនតាំងនៅច្រើន ថែមទាំងកាន់កាប់យ៉ាងមាំទាំតាមភូមិភាគខ្លះ» ។ សីហនុបញ្ជាក់ថា ៖ តាមតំបន់មួយចំនួន «ដំណើរឆ្លងកាត់ត្រូវបានហាមឃាត់ ហើយគេត្រូវផ្អាកដំណើរព្រោះពួកយៀកកុងនិងយៀកណាមខាងជើងនៅទីនោះច្រើន» ។

ពេញមួយឆ្នាំ១៩៦៩, ប្រតិបត្តិការទាំងឡាយត្រូវបានបំពេញដោយកងទ័ពខ្មែរប្រឆាំងពួកកុម្មុយនិស្តយួន, បញ្ជីរាយរាប់ពីការពើបប្រយុទ្ធគ្នា ត្រូវបានចេញផ្សាយទៀងទាត់ ជាមួយបញ្ជីរៀបរាប់ពីការខូចបង់ ។ ស្តីអំពីអ្នកទោសនៃរណសិរ្សរំដោះជាតិយៀកកុង ដែលត្រូវចាប់បានជាឈ្លើយ សីហនុបានប្រគល់ជូនស្ថានទូតនៃរដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្នយៀកកុងនៅភ្នំពេញ ។ គឺអនុលេខាធិការនៃគណៈបេសកកម្មទូតនេះ, ង្វៀង-បាឌុង ឬសហសេវិករបស់គេ ង្វៀង-ហ្វាំងគិញ ដែលបានចុះហត្ថលេខាទទួលភារៈជារៀងរាល់លើក បានសារភាពថា អ្នកទោស



ពួកយៀកកុង-យៀកណាមខាងជើងទាំងអស់នេះ បានត្រូវស្តេចសីហនុបញ្ជូនប្រគល់ទៅឲ្យស្ថានទូតយួនយៀកកុងវិញ (ថ្ងៃទី២៩ កក្កដា ១៩៦៩)


PROCES VERBAL DE REMISE DES CINQUANTE TROIS DETENUS MEMBRES DU F.N.L. DU SUD VIETNAM

L'an Mil Neuf Cent Soixante Neuf, le Mardi Vingt Neuf Juillet, à 11 heures, a eu lieu au Ministère des Affaires Etrangères entre M. BOSUR NOUTH KIM SAN, Sous-Directeur des Affaires Politiques du Ministère des Affaires Etrangères du Gouvernement Royal du Cambodge et M. NGUYEN BA DUNG, Représentant de l'Ambassade de la République du Sud-Vietnam, la remise des cinquante trois détenus membres du Front National de Libération dont les noms figurent dans la liste jointe en annexe, capturés à l'intérieur du territoire du Cambodge au cours de la période allant du 4 Novembre 1968 au 3 Juin 1969 par les éléments des Forces Nationales de Défense Cambodgienne.

M. NGUYEN BA DUNG, Représentant de l'Ambassade de la République du Sud-Vietnam, déclare par la présente prendre en charge ces cinquante trois détenus membres du FNL qui sont en bonne santé et décharge le Gouvernement Royal du Cambodge toutes responsabilités à partir de cette date.

Fait à Phnom-Penh, le 29 Juillet 1969,

NGUYEN BA DUNG BOSUR NOUTH KIM SAN

គំរូមួយនៃសេចក្ដីរាយការណ៍ ៖ ខាងឆ្វេងចុះហត្ថលេខាដោយ ង្វៀង-បាឌុង និងខាងស្ដាំដោយលោកឌឿ-នុតគីមសាន (សព្វថ្ងៃលោកកំពុងរស់នៅឯសហរដ្ឋអាមេរិក ។

យៀកកុង មានសុខភាពល្អ ហើយបានសំដែងការជំពាក់គុណចំពោះសប្បុរសធម៌ និងក្ដីសណ្ដោសរបស់សីហនុ ។ នៅថ្ងៃទី៨កក្កដា១៩៦៩, អ្នកទោសយៀកកុង២០នាក់ត្រូវបានដោះលែង, នៅថ្ងៃទី២៩ យៀកកុង៥៣នាក់ទៀតដែលត្រូវបានចាប់ខ្លួន ពីខែវិច្ឆិកា១៩៦៨ ត្រូវបានដោះលែងទៀត, នៅថ្ងៃទី៣១តុលា១៩៦៩ យៀកកុង៩១នាក់ដែលមាន៣៨នាក់ជាភេទស្រីត្រូវបានប្រគល់ទៅរដ្ឋាភិបាលបដិវត្តន៍បណ្ដោះអាសន្នយៀកកុងវិញ, នៅថ្ងៃទី១៨វិច្ឆិកា មានការដោះលែងយៀកកុង២២នាក់, នៅថ្ងៃទី១២ធ្នូ ៖ ១១នាក់, នៅថ្ងៃទី២៦ធ្នូ ៖ ៨នាក់, ហើយទីបំផុត នៅថ្ងៃទី២៧មករា១៩៧០ យៀកកុង១៦នាក់ បានចាកចេញពីជំរំឃុំឃាំងរបស់ខ្មែរ ។

មួយខែបន្ទាប់ពីសន្និសិទសារពត៌មាន, សីហនុឈប់លាក់លៀមស្ងៀតរបស់គាត់ ដោសារភាពទាំងឥតខ្មាស់អៀន នៅថ្ងៃទី២២មេសា១៩៦៩ថា ៖ «ពួកកុម្មុយនិស្តត្រូវតែទទួលស្គាល់ នូវរាល់អ្វីៗដែលគាត់បានបំពេញ ដើម្បីជួយពួកគេនៅកម្ពុជា ។ ជំនួយដល់យៀកកុងនិងយួនខាងជើង បានទទួលពីកម្ពុជា ស្ថិតនៅលើវិស័យទូតនិងវិស័យសម្ភារៈ ។ កម្ពុជាបានផ្ដល់ការជ្រោមជ្រែងគ្រប់បែបផ្សេងៗទៀត ក្នុងបំណងឲ្យយៀកកុងមានលទ្ធភាពសំរាប់តស៊ូ ជាមួយចក្រពត្តិនិយមអាមេរិកាំង ដើម្បីដណ្ដើមយកដែនដីនិងឯករាជ្យរបស់គេមកវិញ» ។

ចំណុចខកចិត្តធំមួយទៀតគឺ «មហាមិត្តចិន» តែម្ដង ដែលចង់រំលំរាជាធិបតេយ្យខ្មែរ ហើយធ្វើកម្ពុជាឲ្យទៅជារដ្ឋកុម្មុយនិស្ត ។ ចិនប្រជាមានិតមានបំណងធ្វើឲ្យបដិវត្តន៍វប្បធម៌របស់គេ ក្លាយទៅជាទំនិញមួយសំរាប់នាំចេញទៅក្រៅប្រទេស

ហើយជនណាក៏ដោយ ដែលមិនមែនជាអ្នកម៉ៅនិយម ត្រូវបានចាត់ទុកជាជនប្រតិកិរិយា ។ ដោយសង្ឃឹមទាំងឥតអំពើ ដើម្បីកែប្រែទស្សនវិស័យរបស់ប៉េកាំង ក្នុងនាមនៃមិត្តភាព, សីហនុបានបញ្ជូនរដ្ឋមន្ត្រីក្រសួងការបរទេសទៅប៉េកាំង, នរោត្តម ភូរិស្សរា, ដែលបានជួបសន្ទនាជាមួយជូ-អេនឡាយ នៅថ្ងៃទី១៧សីហា១៩៦៨ ។ យោងតាមសេចក្ដីរាយការណ៍របស់នរោត្តន-ភូរិស្សរាចំពោះសីហនុ, នាយករដ្ឋមន្ត្រីចិនបានបញ្ជាក់ដោយត្រង់ៗថា ៖

«មហាបដិវត្តន៍វប្បធម៌ ប្រហែលមានជះឥទ្ធិពលទៅលើអាណិកជនចិននៅកម្ពុជា ។ ជ្រួតជ្រាបដោយសេចក្ដីស្នេហាចំពោះមាតុភូមិរបស់ខ្លួន, អាណិកជនចិនទាំងឡាយ បានបំពេញសកម្មភាពដោយឯងៗ ។ ជាអំពើដែលគេអាចទទួលព្រមបាន ។ សម្ដេចនរោត្តម-សីហនុទ្រង់យល់ច្បាស់ហើយ ។ ប៉ុន្តែរដ្ឋាភិបាលចិន មិនដែលបានជំរុញអាណិកជនទាំងនេះ ឲ្យធ្វើអន្តរាគមន៍ទៅលើកិច្ចការផ្ទៃក្នុងរបស់កម្ពុជាទេ ។ ប្រសិនបើអាណិកជនចិនបានរំលោភច្បាប់ជាធរមានរបស់កម្ពុជា ក្នុងនាមជាប្រទេសមានអធិបតេយ្យភាព មានសិទ្ធិ ដើម្បីដោះស្រាយបញ្ហានេះ ។ ពេលត្រឡប់វិញ យើងសង្ឃឹមថា សកម្មភាពធម្មតារបស់អាណិកជនចិននៅកម្ពុជា និងសិទ្ធិរបស់គេ ព្រមទាំងផលប្រយោជន៍ស្របច្បាប់ និងបានទទួលកិច្ចការពារពីរាជរដ្ឋាភិបាលខ្មែរ» ។

ដោយមានបញ្ហាឲ្យបោះពុម្ពផ្សាយសេចក្ដីរាយការណ៍ខាងលើនេះ, សីហនុបានសរសេរបន្ថែមដោយផ្ទាល់ដៃថា ៖ «មានចិនខ្លះ, ហ៊ឹះ, បានជ្រៀតជ្រែកដោយច្បាស់ក្រឡែតពេក នៅក្នុងដង្ហើមនៃនយោបាយរបស់ខ្មែរ, ហើយនៅក្នុងទឹកដីរបស់ខ្មែរ បានដឹកនាំសកម្មភាពខាងមនោគមវិជ្ជា ដែលមិនសមស្របជាមួយសិទ្ធិនានាដែលជនបរទេសក្នុងប្រទេសមួយ ប្រកបដោយអធិបតេយ្យភាព ហើយដែលមិនមែនជាប្រទេសរបស់ខ្លួនអាចទទួលយក, មិនសមស្របជាពិសេស ជាមួយមិត្តភាពឥតល្អក់កករ ដែលចងភ្ជាប់ប៉េកាំងនិងភ្នំពេញ តាំងពីឆ្នាំ១៩៥៦» ។

ប៉ុន្តែ, ដោយមូលហេតុនៃភាពសោះអង្គើយក្នុងការសន្ទនា រវាងជូ-អេនឡាយ និងនរោត្តម-ភូរិស្សរា, ខាងភាគីកម្ពុជា, គេបានទាំងនិយាយរហូតដល់ ការហៅអគ្គរាជទូតខ្មែរ ទ្រឿង-កាង និងបុគ្គលិកប្រចាំស្ថានទូតទាំងអស់នៅប្រទេសចិនកុម្មុយនិស្ត ឲ្យត្រឡប់មកភ្នំពេញវិញ ។ ប៉ុន្តែ, ទំនាក់ទំនងពុំត្រូវបានកាត់ផ្ដាច់ទេ ហើយតាមការទទូចសុំផ្ទាល់ខ្លួនពីជូ-អេនឡាយ សីហនុយល់ព្រមទុកអគ្គរាជទូតនិងអង្គភាពទូតនៅប៉េកាំងដដែល ។ ប៉ុន្តែនៅចំពោះមុខគ្រោះថ្នាក់រីកដាលនៃវិទ្ធង្សនារបៀបម៉ៅនិយមនេះ, នៅថ្ងៃទី១កញ្ញា១៩៦៧, សីហនុបានសំរេចចិត្តដើម្បីរំលាយរាល់សមាគមមិត្តភាពចិននៅក្នុងប្រទេស ។ សីហនុបានបង្ហាញចំពោះមុខអ្នកសារពត៌មានអំពីមូលហេតុនៃដំណោះស្រាយនេះ ៖ «សមាគមទាំងនេះ បានក្លាយជាអង្គការសំរាប់ឃោសនា និងអង្គការសំរាប់រំលាយរបបដឹកនាំ...។ គេហ៊ានរហូតដល់បង្រៀន

យុវជន កម្មកររបស់យើង ឲ្យច្រៀងសរសើរលើកកិត្តិស័ព្ទរបស់បុគ្គលនេះ បុគ្គលនោះនៅបរទេស...» ។

គឺសកម្មភាពរបស់ចិនកុម្មុយនិស្តនិងការតាំងទីរបស់យៀកកុងដ៏មានគ្រោះថ្នាក់ក្នុងកម្ពុជានេះហើយ ដែលជាកត្តាសំរាប់រុញច្រានកម្ពុជាឲ្យស្វែងរកសម្ព័ន្ធភាពផ្លូវទូតឡើងវិញ ជាមួយសហរដ្ឋអាមេរិក នៅខែមេសា១៩៦៩ បន្ទាប់ពីត្រូវបានផ្តាច់នៅខែឧសភា១៩៦៥, ហើយបន្ទាប់ពីការផ្តាច់ទូតជាមួយកូរ៉េខាងត្បូង, ចិនហ្វ័រម៉ូស, យួនខាងត្បូង និងសៀម ។ ប៉ុន្តែ, ហួសពេលហើយ, ការស្នើររកជំនួយផ្នែកយោធាពីសហរដ្ឋអាមេរិក ត្រូវបញ្ច្រាសគ្នាជាមួយកម្មវិធីរបស់ និច-សុន ដែលប្រាថ្នាដកកងទ័ពអាមេរិកាំងចេញពីយួនខាងត្បូង តាំងពីឆ្នាំ១៩៦៨, ហើយការដកកងទ័ពនេះជានិមិត្តរូបនៃការថយចុះនូវឥទ្ធិពលរបស់អង្គការ សន្ធិសញ្ញាអាស៊ីអាគ្នេយ៍, សេអាតូ, ដែលសំរាប់ប្រឆាំងជាមួយឥទ្ធិពលរបស់កុម្មុយនិស្តនៅក្នុងភូមិភាគ ។

❑

# ការប្រឈមមុខរបស់រដ្ឋាភិបាល លន់-នល់ ជាមួយយៀកកុង និងយួនខាងជើង

ចាប់ពីឆ្នាំ១៩៦៧, ផ្ទុយពីការយល់ឃើញរបស់រាស្ត្រខ្មែរស្លូតត្រង់, កិត្យានុភាពផ្ទាល់របស់សីហនុ បានត្រឹមតែចុះថយបន្តិចម្តងៗ, ប៉ុន្តែតាមពិត ដើម្បីឈានទៅដល់ក៏រិតទាបបំផុត នៅរដូវក្តៅនៃឆ្នាំ១៩៦៩, ដែលគេឈប់រុញរាក្នុងការទិតៀនគាត់សូម្បីក្នុងទីសាធារណៈ ស្តីពីវត្តមាននៃពួកកុម្មុយនិស្តយួននៅកម្ពុជា ។ សីហនុបានទទួលស្គាល់ ដល់ការជ្រៀតចូលនិងការតាំងជាមូលដ្ឋាន ដែលជាមណ្ឌលសំរាប់សំរាកកាយ, ជំរំហ្វឹកហ្វឺន, មន្ទីរពេទ្យ, ឃ្លាំងសំរាប់តម្កល់អាវុធ និងស្បៀងអាហារជាដើម ។ សីហនុបានទាំងបោះពុម្ពផ្សាយក្នុងទស្សនាវដ្តី «សង្គរាស្ត្រនិយ» នៅខែមិថុនា១៩៦៩ នូវសេចក្តីស្រង់ អំពីការសន្ទនា ដែលបានប្រព្រិត្តទៅនៅថ្ងៃទី២៩ឧសភាឆ្នាំដដែល ហើយដែលតាមការណែនាំរបស់គាត់ រវាងរដ្ឋទូតនៃយួនខាងជើង ង្វៀង-ធឿង និងរដ្ឋទូតនៃរណសិរ្សយៀកកុង ង្វៀង-វ៉ាន់ហៀវ ជាមួយឧត្តមសេនិយ លន់-នល់ ។

យោងតាមសេចក្តីរាយការណ៍នេះ, ឧត្តមសេនិយ លន់-នល់, កាលនោះជាអនុប្រធាននៃក្រុមប្រឹក្សារដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការពារជាតិបានរាយការណ៍ជូនរដ្ឋទូតរបស់យួនទាំងពីរថា ៖ «តាំងពីមួយរយៈកាលមកហើយ យើងសង្កេតឃើញថា វត្តមាននៃពលទាហានរបស់លោក បានក្លាយជាការកាន់កាប់ពិតប្រាកដ